


# ដើរឆ្ពោះទៅកាន់ទ្វារដ៏វិសុទ្ធ

## ឆ្នាំមហាករុណាទិគុណ
## សម្តេចព្រះហឫទ័យប្រណីសន្តោស

០៨ ធ្នូ ២០១៥ - ២០ វិច្ឆិកា ២០១៦



សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ

## អារម្ភកថា

*" សូមបងប្អូនមានចិត្តមេត្តាករុណា ដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណាដែរ"* ពិតជាបាវចនាសម្រាប់ឆ្នាំនៃមហាករុណាទិគុណ។

យើងមានភស្តុតាង អំពីព្រះហឫទ័យអាណិតមេត្តារបស់ព្រះបិតា គឺព្រះអង្គសព្វព្រះហឫទ័យអាណិតមេត្តាដល់យើងជានិច្ច ទ្រង់មិនសូមឲ្យយើងសងគុណឡើយ។ ពេលណាយើងអង្វរព្រះអង្គទ្រង់យាងមកជួយយើង... ព្រះបិតាយាងមកសង្គ្រោះយើងឲ្យរួចពីភាពទន់ខ្សោយរបស់ខ្លួន។

ព្រះអង្គជួយយើងឲ្យទទួលស្គាល់ថា ព្រះអង្គគង់នៅជាមួយយើង គឺទ្រង់គង់នៅក្បែរយើង។ ប្រសិនបើយើងចាប់ អារម្មណ៍នឹងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គជារៀងរាល់ថ្ងៃ នោះយើងក៏មុខជានឹងមានចិត្តមេត្តាករុណាចំពោះមនុស្សទាំងអស់ដែរ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ អភិបាលព្រះសហគមន៍ក្រុងរ៉ូម




## បងប្អូនជាទីស្រឡាញ់!

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្វ អញ្ជើញព្រះសហគមន៍ទាំងមូលឲ្យចាត់ទុកឆ្នាំខាងមុខនេះជាឆ្នាំមហាករុណាទិគុណ គឺឆ្នាំមហាករុណាទិគុណនេះចាប់ផ្ដើមថ្ងៃទី០៨ធ្នូ ត្រូវនឹងបុណ្យគោរពនាងម៉ារី ដែលមិនជំពាក់បាប ហើយចប់នៅថ្ងៃ ២០ វិច្ឆិកា ឆ្នាំ២០១៦ ត្រូវនឹងថ្ងៃអាទិត្យគោរពព្រះគ្រីស្ត ជាព្រះមហាក្សត្រនៃពិភពលោក។

ពិភពលោកយើងនេះ តែងតែរងទុក្ខដោយកើតសង្គ្រាម ដោយមានហិង្សា និងដោយមនុស្សស្អប់គ្នា។

ព្រះបិតាប្រទានធម៌មេត្តាករុណាទុកជាមាគ៌ាតែមួយគត់ ដើម្បីឲ្យមនុស្សជាតិយើង អាចស្រុះស្រួលគ្នា និងអាចរស់នៅដូចបងប្អូនបាន ប្រកបដោយសេចក្ដីសុខសាន្ត និងដោយសុខដុមរមនា។ ភូមិភាគយើងត្រូវតែសប្បាយរីករាយ ដោយទទួលឆ្នាំមហាករុណាទិគុណនេះទុកជាពេល ដែលព្រះជាម្ចាស់ប្រណីសន្ដោសមកយើង យើងក៏ត្រូវយកចិត្តទុកដាក់ប្រែចិត្តគំនិតឲ្យបានជាថ្មី ដោយសម្រុះ-

សម្រួលខ្លួនជាមួយព្រះបិតា ហើយសម្រុះសម្រួលជាមួយបងប្អូន។

ចាប់តាំងពីឆ្នាំ ២០១៤មក យើងរស់នៅតាមឆ្នាំបង្ហាញមេត្តាករុណា គឺនៅឆ្នាំដើមដំបូង យើងបានយកអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរសមកធ្វើជាគំរូណែនាំយើង ឲ្យយកចិត្តទុកដាក់ទទួលអ្នកដទៃទុកជាបងប្អូនរបស់ខ្លួនដោយចិត្តមេត្តាករុណា។ នៅឆ្នាំបន្ទាប់(២០១៥) យើងបានសម្លឹងមើលព្រះយេស៊ូដែលបានលាងជើងក្រុមសាវ័ក គឺព្រះអង្គបានណែនាំយើង ឲ្យបម្រើដោយសេចក្ដីស្រឡាញ់តាមសមត្ថភាព។ ក្នុងឆ្នាំទីបីនេះ(២០១៦) យើងនឹងសម្លឹងមើលព្រះបិតាទទួលកូន ដែលវង្វេងនិងត្រឡប់មកវិញ ហើយទទួលស្គាល់កំពូលនៃសេចក្ដីស្រឡាញ់ គឺស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា។

នៅថ្ងៃទី១០ ធ្នូ ២០១៥ យើងនឹងបើកទ្វារដ៏វិសុទ្ធសម្រាប់ភូមិភាគយើងជាផ្លូវការនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី។ បន្ទាប់មកគឺនៅថ្ងៃ១៣ ធ្នូ ២០១៥ យើងនឹងបើកទ្វារដ៏វិសុទ្ធនៅព្រះវិហារសន្តៈយ៉ូសែប រួមជាមួយមរណសាក្សីរបស់យើង។

ក្រោយមកទៀត គឺនៅថ្ងៃ០១ មករា ២០១៦ យើងនឹងបើកទ្វារដ៏វិសុទ្ធនេះនៅភូមិ អរិយក្សត្រ រួមជាមួយព្រះនាងម៉ារីជាមហាក្សត្រីនៃទន្លេមេគង្គ។

ខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗក្នុងភូមិភាគភ្នំពេញ ឲ្យធ្វើបូជនិយចរនៅកន្លែងទាំងបីក្នុងឆ្នាំដ៏វិសុទ្ធនេះ។

ខ្ញុំសូមអញ្ជើញបងប្អូន ឲ្យចូលរួមក្នុងពិធី និងកិច្ចការផ្សេងៗ

ក្នុងឆ្នាំខាងមុខនេះជាពិធី និងជាកិច្ចការដែលអាចជួយណែនាំយើងឲ្យប្រែចិត្តគំនិតយ៉ាងពិតប្រាកដ។

(សូមមើលប្រក្រតីទិនខាងក្រោម)។ តាំងពីពេលនេះតទៅតាមសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ខ្ញុំសូមអញ្ជើញបងប្អូនម្នាក់ៗឲ្យរៀបចំខ្លួននឹង "រស់នៅស្របតាមស្នាព្រះហស្តនៃមេត្តាករុណា ទាំងខាង-វិញ្ញាណ ទាំងខាងរូបកាយ" ដើម្បីឲ្យបងប្អូនធ្វើជាសញ្ញាសម្គាល់សម្តែងព្រះហឫទ័យអាណិតមេត្តាដ៏ធំទូលំទូលាយ របស់ព្រះបិតាចំពោះមនុស្សម្នាក់ៗ ជាពិសេស ចំពោះអ្នកតូចតាចដែលមានគ្នាជាច្រើនក្នុងសង្គមយើង។ សូមឲ្យបងប្អូនស្រុះស្រួលគ្នាក្នុងចិត្ត និងស្រុះស្រួលគ្នាក្នុងក្រុមគ្រួសារ ហើយស្រុះស្រួលគ្នាក្នុងសហគមន៍គ្រីស្តបរិស័ទយើង និងក្នុងប្រទេសយើង ដែលហៀបនឹងចូលក្នុងទីផ្សាររួមដ៏ធំទូលំទូលាយនៃសមាគមអាស៊ាន។ ព្រះជាម្ចាស់ជាតួនៃធម៌មេត្តា ដូច្នេះយើងត្រូវតែធ្វើជាសញ្ញាសម្គាល់អំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

សូមបងប្អូនបានប្រកបដោយសេចក្តីសុខសាន្ត និងដោយអំណរសប្បាយ។

អូលីវីយេ មីឆែលម៉ារីហាស្លេរ

ជាអភិបាលរបស់បងប្អូន

# ធម៌សម្រាប់ឆ្នាំនៃធម៌មេត្តាករុណា
## (សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ)

- បពិត្រព្រះយេស៊ូគ្រីស្ត! ព្រះអង្គបានបង្ហាត់បង្រៀនយើងខ្ញុំ ឲ្យមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណាដែរ។

- ព្រះអង្គមានព្រះបន្ទូលថា អ្នកមើលព្រះអង្គក៏មើលព្រះបិតាឃើញដែរ សូមព្រះអង្គសម្តែងព្រះភក្ត្រ នោះយើងខ្ញុំនឹងទទួលការសង្គ្រោះហើយ។

- ព្រះអង្គបានទតមើលលោកសាខេ និងលោកម៉ាថាយ ដោយព្រះហឫទ័យស្រឡាញ់ នោះលោកទាំងពីរក៏រួចផុតពីខ្ញុំបម្រើ នៃចិត្តលោភលន់ចង់បានប្រាក់។

- ព្រះអង្គបានទតមើលស្រ្តីដែលប្រាសចាកសីលធម៌ នោះនាងក៏រួចផុតពីបំណងត្រេកត្រអាលរបស់មនុស្សដូចគ្នា។

- ព្រះអង្គបានទតមើលលោកសិលា ដែលបានក្បត់ព្រះអង្គ នោះទើបលោកយំទាំងមានចិត្តសោកស្តាយ។

- ព្រះអង្គបានសន្យាឲ្យចោរ ដែលប្រែចិត្តគំនិតចូលស្ថានបរមសុខ សូមព្រះអង្គប្រោសឲ្យយើងខ្ញុំម្នាក់ៗ ចេះស្តាប់ព្រះបន្ទូលដែលព្រះអង្គប្រាប់នាងសាម៉ារីថា ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់។

- ព្រះអង្គជាព្រះភក្ត្ររបស់ព្រះបិតា ដែលមនុស្សមើលមិន

ឃើញព្រះជាម្ចាស់ បានសម្តែងឫទ្ធានុភាពដោយលើកលែងទោស និង ដោយមានព្រះហឫទ័យមេត្តាករុណា។

- សូមប្រោសឲ្យព្រះសហគមន៍ ធ្វើជាព្រះភក្ត្ររបស់ព្រះអង្គ ដែលមនុស្សអាចមើលឃើញបាន ព្រះអង្គជាព្រះអម្ចាស់ដែលមានព្រះជន្មថ្មីដ៏រុងរឿង។

- ព្រះអង្គសព្វព្រះហឫទ័យឲ្យអ្នកបម្រើរបស់ព្រះអង្គ ជាមនុស្សទន់ខ្សោយ មានចិត្តមេត្តាករុណាដ៏ពិតប្រាកដចំពោះអស់អ្នកដែលវង្វេង និងល្ងង់ខ្លៅ។

- សូមប្រោសឲ្យអស់អ្នក ដែលនិយាយរកអ្នកបម្រើម្នាក់នោះ ដឹងថា ព្រះជាម្ចាស់រង់ចាំគេ ស្រឡាញ់គេ និងអត់ទោសឲ្យគេ។

- សូមប្រទានព្រះវិញ្ញាណរបស់ព្រះអង្គ សូមញែកយើងខ្ញុំទាំងអស់គ្នាដោយព្រះវិញ្ញាណនោះផង។

-សូមឲ្យឆ្នាំនៃមហាករុណាទិគុណនេះទៅជាឆ្នាំ ដែលព្រះអម្ចាស់ប្រណីសន្តោស។

- សូមឲ្យព្រះសហគមន៍ប្រកាសដំណឹងល្អដល់អ្នកក្រីក្រ និងផ្តល់ដំណឹងអំពីសេរីភាព ដល់អ្នកដែលជាប់ជាឈ្លើយ និងដល់អ្នកដែលត្រូវគេជិះជាន់ធ្វើបាប។

- សូមឲ្យអ្នកខ្វាក់បានមើលឃើញវិញ។

យើងខ្ញុំសូមអង្វរ ព្រះអង្គរួមជា មួយព្រះនាងម៉ារី ជាមាតាប្រកបដោយធម៌មេត្តាករុណា។ ព្រះអង្គមានព្រះជន្មគង់នៅ និងសោយរាជ្យ រួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធជាយូរអង្វែងតរៀងទៅ។ អាម៉ែន។

# ពាក្យប្រស្លាស្តីអំពីព្រះហឫទ័យមេត្តាករុណា

"ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់" (១យហ៤: ៨-១៦)។ ឥឡូវនេះ យើងអាចមើលឃើញនិងស្ទាបសេចក្តីស្រឡាញ់នោះក្នុងការរស់នៅរបស់ព្រះយេស៊ូតាំងពីដើមដល់ទីបញ្ចប់។ ព្រះអង្គបានសម្តែងសេចក្តីស្រឡាញ់ជានិច្ច គឺព្រះអង្គសុខចិត្តបូជាជីវិតដោយមិនសុំអ្វីមកសងគុណឡើយ។ អស់អ្នកដែលមកជួបព្រះអង្គក៏មានទំនាក់ទំនង បែបពិសេស ដែលប្លែកពីទំនាក់ទំនងជាមួយ អ្នកដទៃ។ព្រះអង្គសម្តែងសញ្ញាសម្គាល់ដ៏អស្ចារ្យ ជាច្រើន ជាពិសេសសញ្ញាសម្គាល់ ដើម្បីជា ប្រយោជន៍ដល់អ្នកបាបដល់ជនក្រីក្រ ដល់អ្នក រស់នៅជាយសង្គមដល់អ្នកជំងឺនិងដែល ឈឺចុកចាប់។ ព្រះអង្គបានសម្តែង សញ្ញាសម្គាល់ប្រកបដោយធម៌មេត្តា ករុណាជានិច្ច។ ក្នុងព្រះអង្គ អ្វីៗ ទាំងអស់សុទ្ធតែសម្តែងអំពីធម៌មេត្តារុណា។ ពេលព្រះយេស៊ូឃើញបណ្តាជនដើរតាមព្រះអង្គអស់កម្លាំង និង ល្វើយ ប្រៀបដូចជាជនដែលវង្វេងដោយគ្មានគង្វាល ព្រះអង្គអាណិតអាសូរដល់គេជាពន់ពេកណាស់ (មថ៩:៣៦)។ ព្រះអង្គព្យាបាលអ្នកជំងឺ ដែលគេនាំមក ព្រោះព្រះអង្គមានព្រះហឫទ័យមេត្តា (មថ១៥: ៣៧) ។ធម៌មេត្តាករុណា



ណែនាំព្រះយេស៊ូក្នុងគ្រប់កាលៈទេសៈ និងធ្វើឲ្យព្រះអង្គឈ្វេងយល់ចិត្តគំនិតអ្នកនិយាយមករកព្រះអង្គ ហើយព្រះអង្គក៏មានព្រះបន្ទូលតបឆ្លើយនឹងតម្រូវការដ៏ជ្រៅរបស់គេផង។ ពេលព្រះយេស៊ូ ជួបស្ត្រីមេម៉ាយ នៅភូមិណាអ៊ីម ដែលដង្ហែសពកូនទោលទៅបញ្ចុះក្នុងផ្នូរ ព្រះអង្គទ្រង់មានព្រះហឫទ័យមេត្តាករុណាយ៉ាងខ្លាំងចំពោះស្ត្រីនោះ ដែលកើតទុក្ខជាទម្ងន់ និងកំពុងតែយំសោក ព្រះអង្គក៏ប្រគល់កូនឲ្យនាងវិញ ទាំងប្រោសឲ្យកូនមានជីវិតថ្មីរួចពីសេចក្តីស្លាប់ (លក៧ : ១៥)។



ព្រះអង្គប្រោសមនុស្សខ្មោចចូលម្នាក់នៅភូមកេរ៉ាសា រួចទ្រង់ចាត់គាត់ឲ្យទៅប្រកាសថា៖ " ចូររៀបរាប់ហេតុ-ការណ៍ទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានប្រោសដល់អ្នក ដោយព្រះហឫទ័យអាណិតអាសូរ " (មក៥: ១៩)។ យើងត្រូវយល់ថាព្រះអង្គត្រាស់ហៅលោកម៉ាថាយ ដើម្បីសម្តែងព្រះហឫទ័យមេត្តាករុណាដែរ។ ព្រះយេស៊ូយាងកាត់នៅខាងមុខកន្លែងទារពន្ធដា ព្រះអង្គសម្លឹងមើលលោកម៉ាថាយ គឺព្រះអង្គទតមើលលោកទាំងសម្តែងធម៌មេត្តាករុណាយ៉ាងក្រៃលែង ព្រះអង្គលើកលែងទោសឲ្យលោក ទោះបីក្រុមសាវ័កមិនសប្បាយចិត្តក្តី ក៏ព្រះអង្គជ្រើសរើសលោកដែលជាអ្នកបាប និងជាអ្នកទារពន្ធឲ្យធ្វើជាសាសានទូតម្នាក់ក្នុងចំណោមក្រុមសាវ័កទាំង១២។

ក្នុងពាក្យប្រស្នា ដែលសម្តែងអំពីព្រះហឫទ័យមេត្តាករុណា

ព្រះយេស៊ូសម្តែងសភាពរបស់ព្រះជាម្ចាស់គឺព្រះជាម្ចាស់ពិតជាព្រះបិតាដែលមិនព្រមចាញ់ ទាល់តែទ្រង់បានលើកលែងទោស និងឈ្នះការបដិសេធរបស់មនុស្ស ដែលមិនព្រមស្រឡាញ់ព្រះអង្គ ហើយព្រះអង្គ ក៏សម្តែងព្រះហឫទ័យមេត្តាករុណាដល់គេជានិច្ចដែរ។ យើងស្គាល់ ពាក្យប្រស្នាទាំងនោះស្រាប់ហើយគឺពាក្យប្រស្នាស្តី អំពីកូនចៀម ដែលវង្វេងអំពីស្ត្រីម្នាក់ដែលបាត់ ប្រាក់ដួង មួយកាក់ និងអំពីឪពុកដែល មានកូន ពីរនាក់ (លក១៥: ១-៣២)។ ក្នុងពាក្យប្រស្នាទាំង បីនោះ



ព្រះអង្គចង់ពន្យល់ថា ព្រះជាម្ចាស់ពោរពេញដោយអំណរជាពិសេសនៅពេលព្រះអង្គ លើកលែងទោសឲ្យគេ ។ ពាក្យប្រស្នាទាំងបីនោះពិតជាស្នូល នៃដំណឹងល្អ និងនៃជំនឿរបស់យើង ព្រោះមានចែងអំពីធម៌មេត្តាករុណាទុកជាកម្លាំងដែលឈ្នះអ្វីៗទាំងអស់ និងមនុស្សក៏បានពោរពេញដោយធម៌មេត្តាករុណា និងព្រះអង្គលួងលោមចិត្តគេទាំងលើកលែងទោសឲ្យគេផង។ ក្នុងពាក្យប្រស្នាមួយទៀតព្រះ-យេស៊ូបង្រៀនយើងអំពីរបៀបរស់នៅតាមគ្រីស្តសាសនា។ លោកសិលាសួរព្រះយេស៊ូថាតើយើងត្រូវអត់ទោសឲ្យគេប៉ុន្មានដង? "ខ្ញុំសូមប្រាប់អ្នកថា អ្នកត្រូវអត់ទោសឲ្យគេមិនត្រឹមតែប្រាំពីរដងប៉ុណ្ណោះទេ គឺត្រូវអត់ទោសឲ្យគេចិតសិបដងប្រាំពីរដង" (មថ១៧:២២) ។ ក្រោយមក ព្រះអង្គរៀបរាប់ពាក្យប្រស្នាអំពីអ្នកជំពាក់បំណុលដែលគ្មានធម៌មេត្តាសោះ។ ម្ចាស់បំណុលទាមទារបំណុលដ៏សម្បើម

អស្ចារ្យពីគាត់។ ដោយគាត់គ្មានអ្វីសងម្ចាស់ គាត់ក្រាបសូមអង្វរម្ចាស់បំណុល ឲ្យលុបបំណុលនោះចោល។ ម្ចាស់ក៏លុបបំណុលដែរ។ ភ្លាមនោះគាត់ជួបអ្នកបម្រើម្នាក់ដែលជំពាក់ប្រាក់គាត់តែតិចតួចទេ។ គេក្រាបសូមអង្វរឲ្យអាណិតអាសូរតែគាត់មិនព្រមសោះ និងបញ្ជាឲ្យចាប់គេដាក់មន្ទីរឃុំឃាំង។ កាលម្ចាស់បានឮគេនិយាយអំពីរឿងនេះគាត់ខឹងនិងហៅអ្នកបម្រើមកប្រាប់ថា៖ "យើងបានអាណិតមេត្តាអ្នកឯង។ ហេតុដូចម្ដេចបានជាអ្នកឯងពុំព្រមអាណិតមេត្តាដល់គូកនរបស់អ្នកឯងផងដូច្នេះ?"។ ព្រះយេស៊ូបញ្ចប់ថា ៖ "បើម្នាក់ៗមិនព្រមលើកលែងទោសឲ្យ បងប្អូនដោយស្មោះអស់ពីចិត្តទេនោះ ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ព្រះ-អង្គក៏នឹងធ្វើទារុណកម្មបងប្អូនដូច្នោះដែរ" (មថ១៨: ៣៣. ៣៥)។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ
ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម ( MV 8-9 )

# បូជនិយចរ



បូជនិយចរ ជាសញ្ញាសម្គាល់ពិសេស ប្រចាំឆ្នាំដ៏វិសុទ្ធ គឺជានិមិត្តរូប អំពីដំណើរជីវិតរបស់ មនុស្សម្នាក់ៗ។

ពេលមនុស្សរស់នៅ គេដូចជាធ្វើបូជនិយចរ គឺគេធ្វើដំណើររហូតដល់ទិសដៅដែលគេចង់ទៅ។ ម្នាក់ៗត្រូវតែធ្វើបូជនិយចរម៉្យាងតាមកម្លាំងរៀងៗខ្លួន ដើម្បី ឆ្លងទ្វារដ៏វិសុទ្ធនៅក្រុងរ៉ូមនិងនៅគ្រប់ទីកន្លែងឯទៀតៗ។ បូជនិយចរ នឹងទៅជាសញ្ញាសម្គាល់បង្ហាញថាម្នាក់ៗ ដើរឆ្ពោះទៅរកព្រះហឫទ័យមេត្តាករុណា ដែលទាមទារឲ្យខ្លួនប្តេជ្ញាចិត្តបូជាជីវិត។ សូមឲ្យបូជនិយចរដាស់តឿនយើង ឲ្យប្រែចិត្តគំនិតគឺនៅពេលយើងឆ្លងទ្វារដ៏វិសុទ្ធយើងនឹងបណ្តោយខ្លួន ឲ្យព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណាឱបយើង ហើយយើងក៏ប្តេជ្ញាចិត្ត ឲ្យមានចិត្តមេត្តាករុណាចំពោះអ្នកដទៃដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណាដល់យើងដូច្នោះដែរ។

ព្រះអម្ចាស់យេស៊ូបង្ហាញដំណាក់កាល នៃបូជនិយចរនោះជាផ្លូវដែលនាំឲ្យយើងអាចទៅដល់ទិសដៅ គឺថា "កុំថ្កោលទោសអ្នកដទៃឲ្យសោះ នោះព្រះជាម្ចាស់ក៏មិនថ្កោលទោសបងប្អូនដែរ។ កុំវិនិច្ឆ័យដាក់ទោសអ្នកដទៃឲ្យសោះ នោះព្រះជាម្ចាស់ក៏មិនវិនិច្ឆ័យដាក់ទោសបងប្អូនដែរ។ ចូរលើកលែងទោសឲ្យអ្នកដទៃនោះព្រះ

ជាម្ចាស់នឹងលើកលែងទោសឲ្យបងប្អូនដែរ។ ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់បងប្អូនដែរ គឺព្រះអង្គនឹងប្រទាន តាមរង្វាល់ណែនណាន់តាន់តាប់បរិបូណ៌ហូរ-ហៀរដល់បងប្អូន ដ្បិតបងប្អូនវាល់ឲ្យអ្នកដទៃតាមរង្វាល់ណា ព្រះជាម្ចាស់នឹងវាល់ឲ្យបងប្អូនតាមរង្វាល់នោះដែរ" (លក៦:៣៧-៣៨)។ មុនដំបូង ព្រះយេស៊ូមានព្រះបន្ទូលទូន្មានថា "កុំឲ្យថ្កោលទោសអ្នកដទៃ កុំវិនិច្ឆ័យដាក់ទោសគេ"។ ប្រសិនបើយើងមិនចង់ឲ្យ ព្រះជាម្ចាស់វិនិច្ឆ័យដាក់ទោសយើង នោះយើងមិនត្រូវប្រព្រឹត្តដូចចៅក្រមដែលវិនិច្ឆ័យដាក់ទោសគេឲ្យសោះ។ ធម្មតាមនុស្សតែងវិនិច្ឆ័យដាក់ទោសគេ ដោយគិតតែអំពីអ្វីដែលគេមើលឃើញខាងក្រៅប៉ុណ្ណោះ ផ្ទុយទៅវិញព្រះបិតាឈ្វេងយល់ដល់ជម្រៅចិត្តគំនិត។ យើងដឹងថា ពាក្យដែលហូរពីចិត្តច្រណែនឈ្នានីសធ្វើបាបអ្នកដទៃខ្លាំងណាស់។ អ្នកមួលបង្កាច់បងប្អូននៅពេលបងប្អូនមិនស្ថិតនៅជាមួយ គឺណែនាំឲ្យគេយល់ខុសអំពីបងប្អូន ហើយបង្ខូចកិត្តិយសរបស់គេ និងធ្វើឲ្យគេត្រូវរបួស ដោយពាក្យចចាមអារ៉ាម។ បើយើងគិតតាមរបៀបដែលបង្កើតផលវិញពាក្យ "កុំថ្កោលទោសកុំវិនិច្ឆ័យដាក់ទោសអ្នកដទៃ" មានអត្ថន័យថាត្រូវទទួលអ្វីៗដ៏ល្អក្នុងមនុស្សគ្រប់ៗរូប កុំឲ្យគេឈឺចុកចាប់ដោយយើងវិនិច្ឆ័យគេដោយប្រកាន់តែមួយចំណែក ដូចជាអួតថា ខ្លួនដឹងសព្វគ្រប់ទាំងអស់។ សេចក្តីនេះមិនទាន់គ្រប់គ្រាន់ទេ ដើម្បីបញ្ជាក់អត្ថន័យនៃមេត្តាករុណា គឺព្រះយេស៊ូសូមឲ្យយើងលើកលែងទោស និងផ្តល់អំណោយដល់គេថែមទៀតផង គឺឲ្យយើងនាំការលើកលែងទោស

ឲ្យគេព្រោះយើងទទួលស្គាល់ថា ព្រះបិតាបានលើកលែងទោសឲ្យយើងរួចហើយ។ យើងមានចិត្តទូលំទូលាយព្រោះព្រះបិតាមានព្រះហឫទ័យសប្បុរសយ៉ាងធំទូលំទូលាយមកយើងដែរ"។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ( MV14 )

## ដំណើរបូជនីយចរសម្រាប់ភូមិភាគភ្នំពេញ




ទ្វារដ៏វិសុទ្ធនៅភ្នំពេញថ្មី




មរណសាក្សីនៅ
ព្រះវិហារសន្តៈយ៉ូសែប

ព្រះនាងម៉ារីជាក្សត្រី
នៃទន្លេមេគង្គ
នៅអរិយក្សត្រ



# យោបល់អំពីកម្មវិធី

មកដល់មណ្ឌលភ្នំពេញថ្មីនៅពេលល្ងាចមុនថ្ងៃធ្វើបូជនិយចរ។

- ម៉ោង០៥.០០ល្ងាច ៖ មកដល់។

- ម៉ោង០៦.០០ល្ងាច ៖ អាហារពេលល្ងាច។

- ម៉ោង០៧.៣០ល្ងាច ៖ រាត្រីអធិដ្ឋានក្នុងព្រះវិហារសន្តៈសីលា និងសន្តៈប៉ូល។ អគ្គសញ្ញាលើកលែងទោស។

- ម៉ោង ០៦.៣០ព្រឹក ៖ ស្រស់ស្រូបអាហារពេលព្រឹក។

-ម៉ោង០៧.៣០ព្រឹក៖ ពិធីឆ្លងទ្វារនៃព្រះហឫទ័យមេត្តាករុណា។ សូត្រផ្គាំ១០ដង នៅខាងមុខបដិមាព្រះនាងម៉ារីសូត្រធម៌ឱព្រះបិតាធម៌ នៃមហាករុណាទិគុណពាក្យអង្វរតាមសំណូមពរសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ និងរបស់ព្រះសហគមន៍។ ការបង្រៀនយ៉ាងខ្លីអំពីព្រះហឫទ័យមេត្តាករុណានៅខាងមុខបដិមាព្រះនាងម៉ារីឬ នៅព្រះវិហារសន្តៈសិលានិងសន្តៈប៉ូល។

-ម៉ោង០៩.៣០ព្រឹក ៖ ចេញដំណើរទៅព្រះវិហារសន្តៈ យ៉ូសែប។

-ម៉ោង១០.៣០ព្រឹក ៖ មើលពិពណ៌អំពីមរណសាក្សី។ អធិដ្ឋាននៅព្រះវិហារសន្តៈយ៉ូសែប។

ម្នាក់ៗនៅស្ងៀម។ពីធីនមស្សការអគ្គសញ្ញាដ៏វិសុទ្ធ។ពិធីលើកលែងទោស។

- ម៉ោង១២.០០ ថ្ងៃត្រង់ ៖ ទទួលទានអាហារថ្ងៃត្រង់។

- ម៉ោង១៣.០០រសៀល ៖ ចេញដំណើរទៅអរិយក្សត្រ។

-ម៉ោង១៤.៣០រសៀល ៖ ពិធីអង្វរម្ចាស់ក្សត្រីនៃទន្លេមេគង្គ។ អភិបូជា។

# ទ្វារដ៏វិសុទ្ធនៅភ្នំពេញថ្មី



.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

.....................................................................................

..................................................................................... ។

# មរណសាក្សីនៅព្រះវិហារសន្តៈយ៉ូសែប




........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................ ។

# ព្រះនាងម៉ារីជាក្សត្រីនៃទន្លេមេគង្គ
# នៅអរិយក្សត្រ



........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

...................................................................................................................... ។

# កិច្ចការដែលសម្ដែងធម៌មេត្តាករុណា តាមរូបកាយ

ខ្ញុំមានបំណងយ៉ាងខ្លាំងក្នុងឆ្នាំមហាករុណាទិគុណនេះ គឺខ្ញុំចង់ឲ្យគ្រីស្តបរិស័ទរិះគិតអំពីកិច្ចដែលសម្តែងធម៌មេត្តាករុណាទាំងខាងរូបកាយទាំងខាងវិញ្ញាណ។ ការរិះគិតនេះនឹងទៅជារបៀបដាស់មនសិការរបស់ខ្លួនដែលស្ពឹក គឺយើងត្រូវយកចិត្តទុកដាក់ នឹងជនក្រីក្រ ហើយចូលកាន់តែជ្រៅទៅៗ ក្នុងបេះដូងនៃព្រះសហគមន៍។ ព្រះជាម្ចាស់ មានព្រះហឫទ័យមេត្តាករុណាចំពោះជនក្រីក្រលើសគេទាំងអស់។ ព្រះយេស៊ូសម្តែងធម្មទេសនាដែលបង្ហាញអំពីកិច្ចការដែលបញ្ជាក់ចិត្តមេត្តាករុណា ដើម្បីឲ្យយើងអាចយល់ថាក្នុងឋានៈជាសាវ័ករបស់ព្រះគ្រីស្តតើយើងរស់នៅតាមធម៌មេត្តាករុណាឬក៏អត់។ យើងត្រូវធ្វើកិច្ចការដែលបង្ហាញអំពីចិត្តមេត្តាករុណាតាមរូបកាយ គឺផ្តល់អាហារដល់អ្នកដែលឃ្លានផ្តល់ទឹកដល់អ្នកដែលស្រេកផ្តល់សម្លៀកបំពាក់ ដល់អ្នកដែលនៅខ្លួនទទេទទួលជនបរទេស ទៅសួរសុខទុក្ខអ្នកជំងឺបញ្ចុះសពមនុស្សស្លាប់។ យើងក៏មិនត្រូវភ្លេចធ្វើកិច្ចការដែលសម្តែងធម៌មេត្តាករុណាតាមវិញ្ញាណ គឺឲ្យដំបូន្មានដល់អ្នកដែលមានចិត្តសង្ស័យ បង្រៀនមនុស្សល្ងង់ដាស់តឿនអ្នកបាបលួងលោមអ្នក ដែលកើតទុក្ខលើកលែងទោសដល់អ្នកដែលបានធ្វើទោសដល់យើងព្យាយាមស៊ូទ្រាំមនុស្សដែលរំខានយើងអង្វរព្រះជាម្ចាស់ឲ្យមនុស្សរស់និងមនុស្សស្លាប់។

យើងមិនអាចគេចផុតពីព្រះបន្ទូលរបស់ព្រះអម្ចាស់ថា ព្រះអង្គនឹងវិនិច្ឆ័យយើងតាមព្រះបន្ទូលទាំងនោះគឺថា តើយើងបានផ្តល់

អាហារដល់អ្នកដែលឃ្លាននិងឲ្យទឹកដល់អ្នកដែលស្រេកឬក៏អត់? តើ យើងបានទទួលជនបរទេស និងចែកសម្លៀកបំពាក់ដល់អ្នកដែលនៅខ្លួនទទេឬក៏អត់? តើយើងស្ថិតនៅជាមួយអ្នកជំងឺនិងអ្នកដែលជាប់ឃុំឃាំងឬក៏អត់? (មថ២៥: ៣១-៤៥)។ ព្រះអង្គក៏សួរយើងថាតើយើងបានជួយអ្នកដទៃឲ្យចេញពីការសង្ស័យ ដែលបណ្ដាលឲ្យគេភ័យខ្លាច និងឲ្យគេនៅឯកាឯកោជាញឹកញាប់ឬយ៉ាងណា? តើយើងបានឈ្នះអវិជ្ជារបស់មនុស្សរាប់លាននាក់ជាពិសេសក្មេងៗដែលគ្មានជំនួយឲ្យរួចផុតពីភាពក្រីក្រឬយ៉ាងណា? តើយើងបានធ្វើជាបងប្អូនរបស់អ្នកដែលនៅឯកាឯកោ និងអ្នកដែលកើតទុក្ខឬយ៉ាងណា? តើយើងបានអត់ទោសដល់អ្នកដែលបានធ្វើទោសដល់យើងឬយ៉ាងណា? តើយើងបានលះបង់ការគុំកួនគ្រប់យ៉ាង និងសម្អប់គ្រប់បែបដែលបណ្ដាលឲ្យកើតហិង្សាឬយ៉ាងណា? តើយើងស៊ូទ្រាំដូចព្រះជាម្ចាស់ ដែលមានព្រះហឫទ័យអត់ធ្មត់ខន្តីចំពោះយើងឬយ៉ាងណា? នៅទីបញ្ចប់តើយើងបានអធិដ្ឋានធ្វើបងប្អូនទៅលើព្រះអម្ចាស់ឬយ៉ាងណា? ព្រះគ្រីស្តគង់នៅក្នុងចំណោមអ្នកតូចតាចនេះយើងទាំងអស់គ្នា អាចឃើញសាច់ឈាមរបស់ព្រះ អង្គសាជាថ្មីដែលគេធ្វើទារុណកម្មត្រូវរបួស ត្រូវគេវាយនឹងរំពាត់ត្រូវស្រេកឃ្លាន ត្រូវវង្វេង។ល។ និង។ល។ យើងក៏អាចស្ទាបសាច់ឈាមរបស់ព្រះអង្គយើងក៏អាចជួយព្រះអង្គផងដែរ។សូមកុំបំភ្លេចពាក្យរបស់សន្តៈយ៉ូហានដែលគោរពឈើឆ្កាងថា "នៅពេលយើង ជួបព្រះជាម្ចាស់ព្រះអង្គនឹងវិនិច្ឆ័យយើងអំពីសេចក្ដីស្រឡាញ់របស់យើង"។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ(MV15)

# កិច្ចការដែលសម្តែងធម៌មេត្តាករុណា
# ម៉ាថាយ២៥,៣៥-៣៦

## ១. នៅពេលខ្ញុំឃ្លាន
## អ្នករាល់គ្នាបានឲ្យអាហារខ្ញុំបរិភោគ

....................................................................................

....................................................................................

....................................................................................

....................................................................................

....................................................................................

....................................................................................



..........................................

..........................................

..........................................

..........................................

..........................................

..........................................

..........................................

.......................................... ។

## ២. នៅពេលខ្ញុំស្រេក
## អ្នករាល់គ្នាបានឲ្យទឹកខ្ញុំពិសា

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

....................................

....................................

..............................

..............................

..............................

..............................

...............................

...............................

............................ ។



# ៣. នៅពេលខ្ញុំជាជនបរទេស អ្នករាល់គ្នាបានទទួលខ្ញុំឲ្យស្នាក់អាស្រ័យ

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................



...............................................

...............................................

...............................................

...............................................

...............................................

...............................................

............................................... ។

## ៤. នៅពេលខ្ញុំគ្មានសំលៀកបំពាក់ អ្នករាល់គ្នាបានយកសំលៀកបំពាក់មកឲ្យខ្ញុំ

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

....................................................

.............................................

..........................................

.........................................

..........................................

.............................................

...............................................។



## ៥. នៅពេលខ្ញុំមានជំងឺ អ្នករាល់គ្នាបានមកសួរសុខទុក្ខខ្ញុំ

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................

................................................................................................



................................................

................................................

................................................

................................................

................................................

................................................

................................................។

# ៦. នៅពេលខ្ញុំជាប់ឃុំឃាំង អ្នករាល់គ្នាក៏បានមកសួរខ្ញុំដែរ

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

.....................................

.....................................

.....................................

.....................................

.....................................

.....................................

...................................។



# ៧. នៅពេលខ្ញុំស្លាប់ អ្នករាល់គ្នាបានបានបញ្ចុះសពខ្ញុំ



**២០១៦**

**វិស័យទាំងប្រាំមួយ សម្រាប់គ្រីស្ទបរិស័ទភូមិភាគភ្នំពេញអនុវត្ត ធម៌មេត្តាករុណារួមមាន៖**

ជនពិការ

វិស័យអប់រំ

អភិវឌ្ឍន៍ជនបទ

ការការពារធម្មជាតិ

វិស័យុសុខាភិបាល

និងកម្មករនិងជនសំណាកស្រុក។

# ពាក្យអធិដ្ឋាន

## ធម៌ប្រការជំនឿរបស់គ្រីស្តទូត

- ខ្ញុំជឿព្រះបិតា ដ៏មានតេជានុភាពសព្វប្រការជាព្រះបង្កើតមេឃ និងដី។

- ខ្ញុំជឿព្រះយេស៊ូគ្រិស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយ ជាអម្ចាស់យើងខ្ញុំ។ ព្រះអង្គបានចាប់កំណើតជាមនុស្ស ដោយសារ ព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់បានប្រសូតពីព្រះ-នាងព្រហ្មចារិនីម៉ារី។ ព្រះអង្គបានសោយទុក្ខលំបាកនៅជំនាន់លោកប៉ុនពីឡាត់។ ព្រះអង្គត្រូវគេឆ្កាងសោយព្រះទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ ព្រះអង្គបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ឡើងវិញ រួចព្រះអង្គបានយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្តាំព្រះបិតាដ៏មានតេជានុភាពសព្វប្រការ។ ព្រះអង្គនឹងយាងមកវិញ ដើម្បីកាត់ក្តីបាបកុសលឲ្យមនុស្សទាំងរស់ទាំងស្លាប់។

- ខ្ញុំជឿព្រះវិញ្ញាណដ៏វិសុទ្ធ!

- ខ្ញុំជឿព្រះសហគមន៍កាតូលិក និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ ខ្ញុំជឿថា មានការលើកលែងទោសរំដោះបាប ហើយ រូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង។ អាម៉ែន។

## ធម៌ឱព្រះបិតា

ដូចព្រះយេស៊ូបានបង្រៀនប្រដៅយើងខ្ញុំ ហើយតាមបញ្ញារបស់ព្រះអង្គយើងខ្ញុំហ៊ានសូត្រថា៖

ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ! សូមសម្ដែងព្រះបារមី ឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ។ សូមឲ្យព្រះរាជ្យរបស់ព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។ សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការ នៅថ្ងៃនេះ សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោស ឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។ សូមកុំបណ្ដោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច។

## ធម៌បពិត្រព្រះនាងម៉ារី

បពិត្រព្រះនាងម៉ារី!
ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់
សូមព្រះនាងមានអំណរសប្បាយ
ព្រះអង្គគង់នៅជាមួយនាង
ព្រះអង្គបានប្រទានពរដល់នាងលើសស្ត្រីទាំងឡាយ
ហើយទ្រង់ក៏ប្រទានពរដល់បុត្រព្រះនាងដែរ។
ឱ! សន្ដីម៉ារី ជាមាតាព្រះអម្ចាស់!
សូមជួយអង្វរព្រះអង្គអោយយើងខ្ញុំ ជាអ្នកបាបនៅពេលឥលូវនេះ ហើយនៅពេលស្លាប់ផង។ អាម៉ែន។

## ធម៌សូមកោតសរសើរ

*សូមកោតសរសើរព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះអង្គគង់នៅតាំងពីដើមរៀងមក ហើយជាអង្វែងតរៀងទៅ។ អាម៉ែន។*

## របៀបសូត្រផ្គាំប្រចាំថ្ងៃ




ក្នុងការអធិដ្ឋានផ្គាំ យើងនឹកសញ្ជឹងពីព្រឹត្តការណ៍ដ៏អស្ចារ្យមួយដែលព្រះ ជាម្ចាស់បានប្រព្រឹត្តដើម្បីសង្គ្រោះមនុស្សលោក។ ព្រឹត្តិការណ៍ដ៏អស្ចារ្យនោះចែកចេញជា ៤ ចំណែកគឺ៖

### ១. ព្រឹត្តិការណ៍នាំអោយអរសប្បាយ (សូត្រថ្ងៃ ច័ន្ទ និង ថ្ងៃសៅរ៍)



- ព្រះជាម្ចាស់ចាត់ទេវទូតមកជូនដំណឹងនាងម៉ារី
- ព្រះនាងម៉ារីទៅជំរាបសួរនាងអេលីសាបិត
- ព្រះយេស៊ូប្រសូតមកក្នុងលោកយើងនេះ
- នាងម៉ារីបីព្រះឱរសយេស៊ូទៅថ្វាយព្រះជាម្ចាស់
- នាងម៉ារីនិងលោកយ៉ូសែបរកឃើញព្រះកុមារយេស៊ូ ក្នុងព្រះវិហារ។

## ២. ព្រឹត្តិការណ៍សំដែងព្រះពន្លឺ ( សូត្រ ថ្ងៃព្រហស្បត៍ )



- ព្រះយេស៊ូទទួលពិធីជ្រមុជទឹក
- ព្រះយេស៊ូប្រែទឹកអោយក្លាយជាស្រា
- ព្រះយេស៊ូប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់
- ព្រះជាម្ចាស់បង្ហាញសិរីរុងរឿងរបស់ព្រះយេស៊ូ
- ព្រះយេស៊ូបូជាព្រះជន្មសំរាប់មនុស្សលោក។

## ៣. ព្រឹត្តិការណ៍នៃទុក្ខលំបាក( សូត្រ ថ្ងៃ អង្គារ៍ និង ថ្ងៃសុក្រ )



- ព្រះយេស៊ូស្លុតរន្ធត់នៅក្នុងសួនច្បារកេតសេម៉ានី
- ព្រះយេស៊ូត្រូវគេវាយនឹងរំពាត់
- គេបំពាក់មកុដបន្លាលើព្រះយេស៊ូ
- ព្រះយេស៊ូលីឈើឆ្កាង
- ព្រះយេស៊ូសោយទិវង្គត។

## ៤. ព្រឹត្តិការណ៍សំដែងសិរីរុងរឿង ( សូត្រ ថ្ងៃ ពុធ និង ថ្ងៃអាទិត្យ )



- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
- ព្រះយេស៊ូយាងឡើងស្ថានបរមសុខ
- ព្រះវិញ្ញាណយាងមកសណ្ឋិតលើក្រុមសាវ័ក
- ព្រះជាម្ចាស់លើកនាងម៉ារីឡើងស្ថានបរមសុខ
- ព្រះជាម្ចាស់ប្រទានសិរីរុងរឿងឲ្យនាងម៉ារី។

## របៀបសូត្រផ្ដាំប្រចាំថ្ងៃផ្ដាំគោរពព្រះហឫទ័យ មេត្តាករុណា



**សូត្ររួម៖** ឱ! ព្រះបិតា ដែលគង់នៅអស់កល្បជានិច្ច! កូនសូមថ្វាយទៅព្រះអង្គ នូវព្រះកាយព្រះគ្រីស្ត ព្រះវិញ្ញាណ និងទេវភាពរបស់បុត្រដ៏ជាទីស្រលាញ់ របស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត ជាអម្ចាស់យើងខ្ញុំ ដើម្បី លុបលាងទោសកំហុសរបស់យើងខ្ញុំ និងទោសកំហុសរបស់ពិភពលោកទាំងមូល។

**ក្រុមទី១៖** ដោយព្រះលំបាកដ៏សែនវេទនារបស់ព្រះយេស៊ូ។

**ក្រុមទី២៖** សូមមេត្តាអាណិតអាសូរយើងខ្ញុំ និងពិភពលោកទាំងមូល។ (១០ដង)

**សូត្ររួម៖** ឱ! ព្រះជាម្ចាស់ ដ៏វិសុទ្ធប្រកបដោយតេជានុភាព និងដែលគង់នៅអស់កល្បជានិច្ច សូមមេត្តាអាណិតអាសូរយើងខ្ញុំ និងពិភពលោកទាំងមូល។ (៣ដង)

**ចម្រៀង** **កោតសរសើរធម៌មេត្តា**

**បន្ទរ៖** កោតសរសើរធម៌មេត្តាព្រះអង្គ ប្រោសប្រទាន ឱ! ព្រះមហាបេះដូង កូនជឿជាក់លើព្រះអង្គ (២ដង)

ទូលភ្នំកាល់វ៉ារី ទីដែលទ្រង់សោយទីវង្គត ទ្រង់បានបូជាឈាមស្រស់ ដើម្បីសង្គ្រោះរូបកូន ជាជ្រោះនៃក្តីស្រលាញ់ហូរចេញពីបេះដូងព្រះម្ចាស់ ដើម្បីលុបលាងបាបកម្មអោយកូនមានជីវិតថ្មី។

# ពាក្យអធិដ្ឋាន ធម៌មេត្តាករុណា

- ឱ! ព្រះជាម្ចាស់ ដែលប្រកបដោយធម៌មេត្តាករុណា! មានតែព្រះអង្គទេដែលល្អឥតខ្ចោះ។ កូនរត់មកទូលអង្វរសុំក្ដីមេត្តាករុណាព្រះអង្គ។ ទោះបីកូនៗរងទុក្ខវេទនា និងក្ដីប្រមាថរបស់កូនមានទំហំធំពេកក្រៃ។ ក៏កូនៗ នៅតែជឿទុកចិត្តលើសេចក្ដីស្រលាញ់របស់ព្រះអង្គ ព្រោះព្រះអង្គមានធម៌មេត្តាករុណា។ តាំងពីដើមរៀងមក កូនមិនដែលលឺថា អ្នកដែលជឿទុកចិត្តលើក្ដីមេត្តាករុណារបស់ព្រះអង្គត្រូវខកចិត្តឡើយ។

- ឱ! ព្រះជាម្ចាស់ ប្រកបដោយក្ដីមេត្តាករុណាយ៉ាងក្រៃលែង។ ព្រះអង្គ មិនដែលបោះបង់ចោលបុត្រធីតាព្រះអង្គ នៅពេលដែលពួកគេទទួលសារភាពកំហុស ហើយអង្វរសុំក្ដីមេត្តាករុណាពីព្រះអង្គ។ ព្រះអង្គតែងតែប្រោសប្រណីដល់អស់វិញ្ញាណទាំងឡាយដែលរត់មកពឹងសុំក្ដីមេត្តាករុណាពីព្រះអង្គ ទោះបីវិញ្ញាណនោះពោរពេញដោយអំពើបាបយ៉ាងណាក៏ដោយ។ ព្រះយេស៊ូមានព្រះបន្ទូលថា ទោះបីជាលោកិយ៍នេះរលាយបាត់បង់ទៅក៏ដោយ ក៏ក្ដីមេត្តាករុណារបស់ព្រះអង្គ នៅតែការពារអស់ វិញ្ញាណទាំងឡាយដែលបានជឿទុកចិត្តលើព្រះអង្គ។

- ឱ! ព្រះយេស៊ូគ្រីស្ត! ព្រះអង្គជាមិត្តសម្លាញ់នៃអ្នកកំសត់ទុរគត ព្រះអង្គជាព្រះសង្គ្រោះ ជាទីសង្ឃឹមនៃក្ដីសុខសាន្តក្នុងកណ្ដាលសមុទ្រនៃទុក្ខសោក ព្រះអង្គជាពន្លឺដែលបំភ្លឺដំណើរជីវិតកូន។ ព្រះអង្គជាអ្វីៗសព្វសារពើនៃវិញ្ញាណដែលគ្មានទីពឹង។ ព្រះអង្គស្គាល់ពីភាពទន់ខ្សោយរបស់កូន ហើយព្រះអង្គជាអ្នកព្យាបាលដ៏ប្រសើរ។ ព្រះអង្គថ្នាក់ថ្នម និងព្យាបាលរបួសនៃកូនទាំងឡាយ។

អាម៉ែន។



# កាលបរិច្ឆេទដ៏សំខាន់សម្រាប់ភូមិភាគភ្នំពេញ

១/ ១០ ធ្នូ ២០១៥ ពិធីបើកទ្វារដ៏វិសុទ្ធនៅភ្នំពេញថ្មី។

២/ ១៣ ធ្នូ ២០១៥ ពិធីបើកពិពណ៌មរណសាក្សី និង
ធម៌មេត្តាករុណានៅវិហារសន្តៈយ៉ូសែប។

៣/ ១៨ ធ្នូ ២០១៥ អ្នកបម្រើភូមិភាគបម្រើធម៌មេត្តាករុណា
(ពីម៉ោង១៤.៣០-២០.០០)។

៤/ ០១ មករា ២០១៦ ពិធីបើកទ្វារនៃធម៌មេត្តាករុណានៅភូមិ
អរិយក្សត្រ។

៥/ ០៧ មករា ២០១៦ ទិវាបព្វជិតបព្វជិតាសហគមន៍ ជា
កន្លែងសម្តែងការលើកលែងទោស។

៦/ ១០មករា ២០១៦ បុណ្យព្រះយេស៊ូសម្តែងឋានៈរបស់
ព្រះអង្គ (០៣.០០ រសៀល) ។
ពិធីប្រសិទ្ធិពរនៅមណ្ឌលភ្នំពេញថ្មី។

៧/ ១១-១២ មករា ២០១៦ សិក្ខាសាលាជាភាសាបារាំង ៖
ព្រះយេស៊ូ និងមេត្តាករុណាដោយលោកយ៉ូសែប
ដូរេអតីតអភិបាលក្រុងស្រ្តាសប៊ួរ(ប្រទេសបារាំង)។

៨/ ១៨ មករា ២០១៦ សំណាក់ធម៌ សម្រាប់សមាជិក
សម្ពន្ធកាតូលិកដើម្បីសម្តែង
ធម៌មេត្តាករុណា និងការអភិវឌ្ឍ។

៩/ ថ្ងៃអាទិត្យមួយនៅខែ កុម្ភៈ ២០១៦ ទិវាគ្រីស្តបរិស័ទជា
សាសនទូត។

១០/ ០៣ វិច្ឆិកា ២០១៥; ០២ កុម្ភៈ ២០១៦; ២៦ មេសា ២០១៦;
២១ មិថុនា ២០១៦ សំណាក់ធម៌សម្រាប់អស់លោកគ្រូគង្វាល ៖ ធម៌មេត្តាករុណា (ទំនុកតម្កើងពាក្យប្រស្នា គ្រូបាធ្យាយ នៃព្រះសហគមន៍សន្តបុគ្គល )។

១១/ រដូវអប់រំពិសេស ២០១៦ ការបង្រៀនអំពីធម៌មេត្តាករុណា (លោកអូលីវីយេ )។

* ១៤ កុម្ភៈ ថ្ងៃអាទិត្យទី១ ក្នុងរដូវអប់រំពិសេស ៖ ពិធីត្រាស់ហៅ( ជំហ៊ានទី២ ) សំណាក់ធម៌តំបន់ភ្នំពេញជើង និងត្បូងនៅព្រះវិហារសន្តៈយ៉ូសែប។

*២១ កុម្ភៈ ថ្ងៃអាទិត្យទី២ក្នុងរដូវអប់រំពិសេស ៖ សំណាក់ធម៌តំបន់តាកែវ។

*២៨ កុម្ភៈ ថ្ងៃអាទិត្យទី២ក្នុងរដូវអប់រំពិសេស ៖ សំណាក់ធម៌តំបន់កំពត។

*០៤-០៥ មិនា អធិដ្ឋានម្ភៃបួនម៉ោង (នៅគ្រប់តំបន់ នៃភូមិភាគ )។

*០៦ មិនា ថ្ងៃអាទិត្យទី៤ ក្នុងរដូវអប់រំពិសេស ៖ សំណាក់ធម៌តំបន់ភ្នំពេញថ្មី-តាខ្មៅ។

*១៣ មិនា ថ្ងៃអាទិត្យទី៥ក្នុងរដូវអប់រំពិសេស ៖ សំណាក់ធម៌តំបន់មេគង្គ-បាសាក់។

*២០ មិនា ថ្ងៃអាទិត្យគោរពទុក្ខលំបាកព្រះយេស៊ូ ៖ សំណាក់ធម៌តំបន់ក្រុងព្រះសីហនុ។

១២/ ១៦ មិនា ២០១៦ អភិបូជាប្រសិទ្ធិពរលើប្រេង ។
ភ្នំពេញថ្មី ម៉ោង១២ថ្ងៃដល់៨យប់។

១៣/ ០២-០៣ មេសា ២០១៦ ថ្ងៃអាទិត្យលើកតម្កើងព្រះហឫទ័យមេត្តាករុណា (ប្រជុំយុវជនដែលព្រះជាម្ចាស់ត្រាស់ហៅជំនួសពិធីគោរពគង្វាលដ៏សប្បុរសនៅភ្នំពេញថ្មី)។

១៤/ ឧសភា ២០១៦ ទិវាគោរពមរណបុគ្គលនៅតាំងគោក។

១៥/ អាទិត្យចុងក្រោយក្នុងខែឧសភាឬអាទិត្យទី១ ក្នុងខែមិថុនា៖ សំណាក់ធម៌សម្រាប់អស់លោកបូជាចារ្យ។

១៦/ ១៥ ឧសភា ២០១៦ អភិបូជាក្នុងឱកាសបុណ្យបញ្ចទសទិវាគ្រប់សហគមន៍ដែលនិយាយភាសាផ្សេងៗជួបជុំគ្នា។

១៧/ ១២ មិថុនា ២០១៦ មហាករុណាទិគុណសម្រាប់អ្នកជំងឺនិងជនពិការ។

១៨/ ០១-០៤ កញ្ញា ២០១៦ សំណាក់ធម៌សម្រាប់យុវជន យុវនារីទាំងអស់ ៖ ព្រះជាម្ចាស់ត្រាស់ហៅ និងព្រះហឫទ័យមេត្តាករុណា។

១៩/ ២៣-២៤ កញ្ញា ២០១៦ សិក្ខាសាលាសម្រាប់យុវជន និងមនុស្សពេញវ័យ ៖ សេចក្តីស្រឡាញ់ និងមេត្តាករុណា។ គ្រីស្តបរិស័ទជាសាក្សីអំពីយុត្តិធម៌ និងអំពីសេចក្តីពិតក្នុងសង្គមនាបច្ចុប្បន្នកាល។

២០/ ១៣ វិច្ឆិកា ២០១៦ ពិធីបិទឆ្នាំមហាករុណាទិគុណ និងពិធីអរព្រះគុណ(ភ្នំពេញថ្មី)។




www.catholiccambdia.org
www.facebook.com/catholicphnompenh